ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ
**********

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៨៧
ចុះថ្ងៃទី ១៩_០២_២០០៩
សាលដីកា
លេខ : ១០៣ "ខ"
ចុះថ្ងៃទី ២២_១០_២០១០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣_១០_២០១០ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៨៧ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលមានៈ

- ជនជាប់ចោទឈ្មោះ [redacted] **ធីម៉ាយ** ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិវៀតណាម មុខរបរ ជាងធ្វើក្រចក ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្ដីឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ១៨-០៤-២០០៨ ឃុំខ្លួនថ្ងៃទី ២១-០៤-០៨) (**ដើមបណ្ដឹងឧទ្ធរណ៍**) ។

មានលោក [redacted] **វិបុល** មេធាវីការពារ ។

មានលោក [redacted] **សេង** ជាអ្នកបកប្រែភាសា ។

- ជនជាប់ចោទឈ្មោះ [redacted] **អាន់ទឹង** ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិវៀតណាម មុខរបរជាងសំណង់ កើតនៅប្រទេសវៀតណាម ទីលំនៅមុនពេល [redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ១៨-០៤-២០០៨ ឃុំខ្លួនថ្ងៃទី ២១-០៤-០៨ ។

ត្រូវជាប់ចោទពីបទៈ ប្លន់ និងចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២៩ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទផល្លុន ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣២៤ ផ្លូវលំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ (ចុងបណ្តឹងឧទ្ធរណ៍)។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤០៧ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ធីម៉ាយ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៥ ក្រ៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ គ្រប់ចំណុចទាំងមូល។

## ៦ដំណើររឿងមានដូចតទៅៈ

កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោង ៨ព្រឹក នៅតូបលេខ ១៥០ ក្នុងផ្សារក្បាលថ្នល់ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌចំការមន ក្រុងភ្នំពេញ ឈ្មោះ [redacted] ធីម៉ាយ និងបក្សពួកបានធ្វើសកម្មភាពលួចកាបូបលុយរបស់ម្ចាស់តូបឈ្មោះ [redacted] ច័ន្ទផល្លុន ដោយលួចបានហុចបន្តឱ្យក្មេងប្រុសដែលមកជាមួយ រួចនាំគ្នារត់បាត់អស់ ចាប់បានតែឈ្មោះ [redacted] ធីម៉ាយ ក្រោមការសាកសួររបស់អនុប្រធានផ្សារ ជនល្មើសបានប្រាប់លេខទូរស័ព្ទ ០១១ ៩០៩ ៩៦៧ ដើម្បីទាក់ទងដោះខ្លួន នៅពេលទំនាក់ទំនងក៏មានការណាត់ជួបគ្នានៅមុខវត្តនិរោធជាមួយម្តាយជនល្មើស លុះដល់ពេលកំណត់សមត្ថកិច្ចឃាត់ខ្លួនអ្នកឧបស្រ្តីនោះមកម្នាក់ឈ្មោះ [redacted] អាន់ទីង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៥ ក្រ៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានសេចក្តីសម្រេចដូចតទៅៈ

១- ឱ្យឈ្មោះ [redacted] អាន់ទីង ភេទប្រុស អាយុ ២៦ឆ្នាំ រួចផុតពីបទចោទប្រកាន់ ពីបទ ប្លន់ ប្រព្រឹត្តនៅខណ្ឌមានជ័យ កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- ផ្តន្ទាទោសឈ្មោះ [redacted] អាន់ទីង ភេទប្រុស អាយុ២៦ឆ្នាំ ជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ០៦ខែ គិតពីថ្ងៃឃុំខ្លួនហើយ នៅពេលអនុវត្តសាលក្រមចប់ត្រូវបញ្ជូនឈ្មោះនេះទៅប្រទេសដើមវិញ។

ពីបទ ចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២៩ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។

៣- ផ្តន្ទាទោសឈ្មោះ [redacted] ធីម៉ាយ ភេទស្រី អាយុ ៤០ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់សរុប ៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួនហើយ នៅពេលអនុវត្តសាលក្រមចប់ត្រូវបញ្ជូនឈ្មោះនេះទៅប្រទេសដើមវិញ។

ពីបទ ប្លន់ និងចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២៩ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។

៤- វត្ថុតាងមាន:

- ទូរស័ព្ទមួយគ្រឿងម៉ាកNOKIA 1200 ពណ៌ទឹកប៊ិច

- ម៉ូតូម៉ាកC១០០ កូរ៉េ ពណ៌ក្រហម លេខតួ លេខម៉ាស៊ីន CT ១០០E:១៤៩៦៤៩៦ ផ្លាកលេខ ស.៣៥២៥ ភព១

- ប័ណ្ណសំគាល់ទោចក្រយានយន្តចំនួន ១សន្លឹក

- លុយចំនួន ១១៣ដុល្លាអាមេរិក

ត្រូវប្រគល់ឱ្យទៅឈ្មោះ [redacted] អាន់ទីង ជាម្ចាស់ដើមវិញ នៅពេលអនុវត្តទោសចប់ ។

- កាបូបចំនួន ២ (ធំ១ តូច១), មួកពណ៌ស១ និងលុយខ្មែរចំនួន ១៥០.០០០រៀល ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

- ទុកសិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] ច័ន្ទផល្លុន ប្តឹងទាមទារសំណងនៅពេលក្រោយ ។

៥- សាលក្រមនេះជំនុំជម្រះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤០៧ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ធីម៉ាយ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៥ ក្រ៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ គ្រប់ចំណុចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នីតិវិធីសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទផល្លុន បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

ជនជាប់ចោទឈ្មោះ [redacted] ធីម៉ាយ ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មិនសុខចិត្ត ដោយតុលាការក្រុងភ្នំពេញផ្តន្ទាទោសខ្លួនធ្ងន់ធ្ងរពេក ដោយចាប់ខ្លួនគ្មានភស្តុតាងទេ ។ ចំពោះកាបូបជារបស់ខ្លួន ហើយក្នុងនោះមាន ៣០០ដុល្លារ និង ៧០.០០០រៀល ។ កាបូបពណ៌ក្រម៉ៅជារបស់ខ្លួន ឯកាបូបពណ៌សមិនមែនជាកាបូបរបស់ខ្លួនទេ ហើយពេលចូលប្រទេសកម្ពុជាខ្លួនគ្មានលិខិតស្នាមអ្វីទេ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់របាយការណ៍ និងក្រោយពីបានពិនិត្យសំណុំរឿង ឃើញថា ជនជាប់ចោទមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់។ ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៥ ក្រ៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

កូនក្ដីខ្លួនបានបដិសេធថា គាត់មិនបានប្រព្រឹត្តទេ សូមក្រុមប្រឹក្សាមេត្តាពិចារណាលើស្ថានសម្រាល ដោយសាលក្រមសម្រេចបណ្ដេញគាត់ចេញពីប្រទេសកម្ពុជា ហើយគាត់សន្យាថា គាត់នឹងចេញពីប្រទេសកម្ពុជាភ្លាមនៅពេលគាត់រួចខ្លួន។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ថ្លឹងថ្លែង តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ ៤០៧ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ធីម៉ាយ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទថា ខ្លួនចូលមកប្រទេសកម្ពុជាគ្មានច្បាប់អនុញ្ញាតទេ ចូលមកកម្ពុជាដើម្បីរកស៊ីធ្វើក្រចកដៃជើង។ កាលពីថ្ងៃកើតហេតុថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ ខ្លួនកំពុងទិញដំឡូងក៏ត្រូវគេចាប់ខ្លួនតែម្ដង ខ្លួនពុំបានលួចលុយគេទេ ដូចការចោទប្រកាន់ទេ។

៣- តាមចម្លើយជនរងគ្រោះជាដើមបណឹងថា កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ ខ្លួនកំពុងលក់ដូរ ស្រាប់តែបាត់កាបូបប្រាក់ ដោយគេលួចបន្ទាប់មកខ្លួនបានចាប់បានស្រីម្នាក់នេះប្រគល់ឱ្យអនុប្រធានផ្សារក្បាលថ្នល់។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ (លួចគ្នាច្រើន) និងចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០០៨ បទល្មើសមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២៩ នៃច្បាប់ស្ដីពីអន្តោប្រវេសន៍។

៥- ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទី ១ បង្កព្យសនកម្មតិចតួចមិនធ្ងន់ធ្ងរ ដូច្នេះ គួរពិចារណាពីស្ថានសម្រាលតាមមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ៤៥ ក្រ៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ តែគួរសម្រាលទណ្ឌកម្មដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៤០៧ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ធីម៉ាយ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៥ ក្រ៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទណ្ឌកម្មក្នុងចំណុចទី ៣ លើជនជាប់ចោទឈ្មោះ [redacted] ធីម៉ាយ ត្រូវសម្រាលមកជា ៣ឆ្នាំ វិញ តាមមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ក្រៅពីនេះទុកនៅដដែល។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៕**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១[illegible]

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]